# កម្មវិធីអ្នកដឹកនាំវ័យក្មេងកម្ពុជា-ឡាវ 2024

## សៀវភៅណែនាំ



# កម្មវិធីអ្នកដឹកនាំវ័យក្មេងកម្ពុជា-ឡាវ 2024

## សៀវភៅណែនាំ



# មាតិកា


3 តើកម្មវិធីអ្នកដឹកនាំវ័យក្មេងកម្ពុជា-ឡាវជាអ្វី ?

5 មាតិកាកម្មវិធី

វគ្គសិក្សាអភិវឌ្ឍន៍ប្រកបដោយចីរភាព

វគ្គសិក្សាភាសាអង់គ្លេសដើម្បីអភិវឌ្ឍន៍

ការអនុវត្តន៍សកម្មភាពគម្រោង

បណ្ដាញសិក្ខាកាម

11 តើអ្នកទទួលបានអ្វីពីកម្មវិធីអ្នកដឹកនាំវ័យក្មេងកម្ពុជា-ឡាវ (CLYLP)

12 ការស្នាក់នៅក្នុងក្រុងAucland នៃប្រទេសនូវែលសេឡង់

14 តើនរណាខ្លះអាចដាក់ពាក្យស្នើសុំចូលរួមកម្មវិធីបាន ?

15 លក្ខណៈវិនិច្ឆ័យជ្រើសរើស




## កម្មវិធីអ្នកដឹកនាំវ័យក្មេងកម្ពុជា-ឡាវ ឆ្នាំ ២០២៤

អង្គការ UnionAID សូមអញ្ជើញយុវជនដែលមានចំណាប់អារម្មណ៍ដាក់ពាក្យស្នើសុំចូលរួមក្នុងកម្មវិធីអ្នកដឹកនាំវ័យក្មេងកម្ពុជា-ឡាវ ឆ្នាំ២០២៤ ដែលមានការគាំទ្រពីក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្ម នៃប្រទេសនូវែលសេឡង់ ។

អ្នកដឹកនាំសហគមន៍វ័យក្មេងមកពីគ្រប់ខេត្ត រាជធានីទាំងអស់ក្នុងប្រទេសកម្ពុជា និងប្រទេសឡាវត្រូវបានអញ្ជើញឱ្យដាក់ពាក្យស្នើសុំសម្រាប់កម្មវិធីដ៏អស្ចារ្យនេះ ដែលកម្មវិធីនេះនឹងចាប់ផ្ដើមតាមរយៈអនឡាញ នៅខែសីហា ឆ្នាំ ២០២៤ និងបន្តនៅប្រទេសនូវែលសេឡង់ក្នុងខែមីនា ឆ្នាំ ២០២៥។

# តើកម្មវិធីអ្នកដឹកនាំវ័យក្មេងកម្ពុជា-ឡាវជាអ្វី?

កម្មវិធីអ្នកដឹកនាំវ័យក្មេងកម្ពុជា-ឡាវ (CLYLP) គឺជាកម្មវិធីពង្រឹងសមត្ថភាពសម្រាប់អ្នកដឹកនាំសង្គមស៊ីវិលវ័យក្មេងដែលកំពុងលេចធ្លោ ។ កម្មវិធីនេះអនុវត្តដោយអង្គការ UnionAID មានទីស្នាក់ការនៅប្រទេសនូវែលសេឡង់ ដោយមានដៃគូសហការជាមួយក្រុមហ៊ុនខេអេហ្វភី (KFP) នៅប្រទេសកម្ពុជា អង្គការទីភ្នាក់ងារចំណេះដឹងសម្រាប់ការអភិវឌ្ឍដោយការចូលរួម (PAKA) នៅប្រទេសឡាវ និងសកលវិទ្យាល័យអុកលេន (Auckland University of Technology - AUT)។ កម្មវិធីបើកដំណើរការសម្រាប់អ្នកចូលរួមមកពីប្រទេសកម្ពុជា និងឡាវ ដើម្បីអភិវឌ្ឍបន្ថែមនូវចំណេះដឹង ជំនាញ និងទំនុកចិត្តរបស់ពួកគេ ។ ដូច្នេះពួកគេអាចពង្រឹងនូវការចូលរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងសហគមន៍ក៏ដូចជានៅក្នុងប្រទេស និងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ឱ្យកាន់តែទូលំទូលាយ។

CLYLP ផ្តល់ឱកាសដល់អ្នកដឹកនាំវ័យក្មេងដើម្បីស្វែងរកគំនិតថ្មីៗ និងវិធីសាស្រ្តឆ្ពោះទៅមុខក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ទាំងនៅក្នុងប្រទេសរបស់ពួកគេ និងប្រទេសនូវែលសេឡង់ ដែលអាចបំផុសគំនិតពួកគេឱ្យគិតប្រកបដោយភាពច្នៃប្រឌិតអំពីបញ្ហាប្រឈមនៅក្នុងសហគមន៍របស់ពួកគេ ។ សិក្ខាកាមអនុវត្តតាមកម្មវិធីដែលធ្វើជាក្រុមរួមគ្នាលើមូលដ្ឋានចម្រុះជាតិ សាសន៍ប្រកបដោយបរិយាបន្ន។ អ្នកដឹកនាំវ័យក្មេងនីមួយៗនឹងស្វែងយល់ពីបញ្ហាប្រឈមជាក់លាក់នៃការអភិវឌ្ឍដែលមានឥទ្ធិពលដល់សហគមន៍របស់ពួកគេ បង្កើត និងកែលម្អសំណួរស្រាវជ្រាវលើប្រធានបទនេះ និងរៀបចំសំណើសុំអនុវត្តគម្រោងដោយមានការចូលរួម។














# មាតិកាកម្មវិធី

កម្មវិធីសិក្សានៃ CLYLP ពាក់ព័ន្ធនឹងការរៀនអនឡាញប្រហែល ២០០ ម៉ោង និងរៀនផ្ទាល់ ១៤ សប្តាហ៍។ កម្មវិធីរួមមានវគ្គសិក្សាចំនួនពីរគឺ៖ **ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងភាសាអង់គ្លេសសម្រាប់ការអភិវឌ្ឍ** ។ វគ្គសិក្សាទាំងពីររួមបញ្ចូលគ្នានូវទ្រឹស្តី និងការអនុវត្ត ដោយផ្តោតលើវិធីសាស្ត្ររៀនដោយអនុវត្តន៍ផ្ទាល់។

## វគ្គសិក្សាអភិវឌ្ឍន៍ប្រកបដោយចីរភាព

វគ្គបណ្តុះបណ្តាលអំពីអភិវឌ្ឍន៍ដោយចីរភាព (SDC) នឹងត្រូវបានបែងចែកជាពីរផ្នែក៖

SDC ផ្នែកទី ១ គឺជាវគ្គសិក្សាក្រៅម៉ោងតាមអនឡាញសិក្សាប្រហែល ១៥០ ម៉ោងផ្តល់នៅពេលដែលសិក្ខាកាមស្ថិតនៅក្នុងប្រទេសកំណើតរបស់ពួកគេ ដោយចាប់ផ្តើមនៅក្នុងខែសីហា ឆ្នាំ ២០២៤ ។

បន្ថែមលើការរៀនតាមអនឡាញ មានសិក្ខាសាលាដោយផ្ទាល់រយៈពេលពីរសប្តាហ៍ដែលនឹងធ្វើឡើងនៅក្នុងប្រទេសកម្ពុជា និងប្រទេសឡាវក្នុងអំឡុងពេលវគ្គសិក្សា SDC ផ្នែកទី ១ សម្រាប់សិក្ខាកាមដើម្បីជួបមិត្តភ័ក្តិ និងក្រុមគ្រូបង្រៀនរបស់ពួកគេ និងដើម្បីសិក្សាឱ្យបានស៊ីជម្រៅ។

SDC ផ្នែកទី ២ គឺជាវគ្គពេញម៉ោង និងដោយផ្ទាល់រយៈពេល ១២ សប្តាហ៍ ដែលនឹងប្រព្រឹត្តទៅនៅប្រទេសនូវែលសេឡង់ ចាប់ផ្តើមនៅខែមីនា ឆ្នាំ២០២៥។














**វគ្គសិក្សាការអភិវឌ្ឍន៍ដោយចីរភាពនឹងអាចឱ្យអ្នកចូលរួមអាច៖**

- ស្វែងយល់ពីគោលការណ៍ និងអនុវត្តន៍នៃការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងប្រទេសកំណើតរបស់ខ្លួន និងប្រទេសនូវែលសេឡង់។
- អនុវត្តការគិតជាប្រព័ន្ធ ដើម្បីយល់ពីបញ្ហាប្រឈមនៃការអភិវឌ្ឍដែលមានលក្ខណៈស្មុគស្មាញ។
- អភិវឌ្ឍជំនាញក្នុងការស្រាវជ្រាវ និងការគិតតាមបែបផែនគំរូ ហើយអនុវត្ត ដើម្បីទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅអំពីបញ្ហាប្រឈមនៃការអភិវឌ្ឍជាក់លាក់មួយ។
- អនុវត្តនូវការរៀនសូត្រលើបញ្ហាដែលឆ្លងកាត់រួមគ្នា បញ្ហាពាក់ព័ន្ធនានា រួមទាំងសិទ្ធិមនុស្សយេនឌ័រ និងបរិយាបន្នសង្គម និងផលប៉ះពាល់បរិស្ថាន។
- បង្កើតជំនាញដែលត្រូវការដើម្បីអភិវឌ្ឍ និងរៀបចំគម្រោង ដោយរាប់បញ្ចូលទាំងការសរសេរគម្រោងសំណើ ការគ្រប់គ្រងគម្រោង និង **MERLA** (ការត្រួតពិនិត្យ ការវាយតម្លៃ ការស្រាវជ្រាវ ការរៀន និងការសម្របខ្លួន);
- បង្កើនជំនាញភាសាអង់គ្លេសរបស់ពួកគេសម្រាប់គោលបំណងវិជ្ជាជីវៈ និងការសិក្សា។

**វគ្គសិក្សាការអភិវឌ្ឍន៍ដោយចីរភាព ផ្នែកទី ២ នៅប្រទេសនូវែលសេឡង់ រួមមាន៖**

ជួបជាមួយនឹងស្ថាប័ន គោលនយោបាយ និងការអនុវត្តនានានៅប្រទេសនូវែលសេឡង់ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដូចជា សិទ្ធិមនុស្ស ដំណើរការប្រជាធិបតេយ្យ និងការអភិវឌ្ឍសហគមន៍ តាមរយៈការសិក្សាក្នុងថ្នាក់រៀន និងចុះតាមមូលដ្ឋានផ្ទាល់។

ទស្សនកិច្ចទៅកាន់ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដូចជា ការអភិវឌ្ឍសហគមន៍ អង្គការយុវជននិងបរិស្ថាន និងរដ្ឋសភា។

ការណែនាំអំពីចំណេះដឹងជនជាតិដើមភាគតិច **Māori** សន្ធិសញ្ញា **Waitangi,** យុទ្ធសាស្ត្រ **Maori** ចំពោះការអភិវឌ្ឍន៍ និងឱកាសស្នាក់នៅកន្លែងម៉ារ៉ា (កន្លែងប្រជុំប្រពៃណី **Maori**)។

សិក្ខាសាលាអំពីជំនាញភាពជាអ្នកដឹកនាំ ដូចជា ការគ្រប់គ្រងអង្គការ និងជំនាញតស៊ូមតិ។

កាលវិភាគនៃដំណើរទស្សនកិច្ចជាមួយអង្គការនានាដែលដោះស្រាយបញ្ហាស្រដៀងគ្នាទៅនឹងបញ្ហាប្រឈមនៃការអភិវឌ្ឍរបស់សិក្ខាកាមផងដែរ ជាលក្ខណៈបុគ្គលឬជាក្រុមតូចៗ ។








## វគ្គសិក្សាភាសាអង់គ្លេសសម្រាប់ការអភិវឌ្ឍ

សិក្ខាកាមនៃកម្មវិធី **CYLP** នឹងអភិវឌ្ឍជំនាញភាសាអង់គ្លេសរបស់ពួកគេសម្រាប់ការងារវិជ្ជាជីវៈតាមរយៈវគ្គសិក្សាភាសាអង់គ្លេសសម្រាប់ការអភិវឌ្ឍ **(EDC)** ។ **EDC** ដំណើរការជាមួយគ្នានឹងវគ្គសិក្សាអភិវឌ្ឍន៍ប្រកបដោយចីរភាពផងដែរ ដោយចាប់ផ្តើមរៀនតាមអនឡាញ និងបន្តនៅប្រទេសនូវែលសេឡង់។ វគ្គសិក្សានេះគាំទ្រដល់សិក្ខាកាមសិក្សាក្នុងវគ្គ **SDC** ដោយមានបង្រៀនលើប្រធានបទ៖

- ភាសាអង់គ្លេសជាក់លាក់សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព
- ភាសាអង់គ្លេសផ្លូវការសមស្របសម្រាប់ការងារវិជ្ជាជីវៈ
- ជំនាញទំនាក់ទំនងផ្ទាល់មាត់ និងសរសេរ
- ការសរសេររបាយការណ៍ស្រាវជ្រាវ និងសំណើសុំមូលនិធិ
- សិក្សាជំនាញសម្រាប់ការរៀនភាសាកាន់តែមានប្រសិទ្ធភាព

វគ្គសិក្សាភាសាអង់គ្លេសសម្រាប់ការអភិវឌ្ឍតាមអនឡាញ ត្រូវការពេលប្រហែល ៤0ម៉ោង៖ សិក្ខាសាលាអនឡាញ ២0 ម៉ោង និងការសិក្សាដោយខ្លួនឯង ២0 ម៉ោង។



មានការគាំទ្រផ្នែកភាសាអង់គ្លេសបន្ថែមសម្រាប់សិក្ខាកាមដែលមានកម្រិតភាសាអង់គ្លេសទាបជាងលក្ខណៈវិនិច្ឆ័យជ្រើសរើស ឬដែលត្រូវការជំនួយបន្ថែមជាមួយភាសាអង់គ្លេសមុនពេលចេញដំណើរទៅកាន់ប្រទេសនូវែលសេឡង់។

## ការអនុវត្តគម្រោងសកម្មភាព
## — កម្ពុជា/ឡាវ

សិក្ខាកាមនឹងចាត់ចែងគម្រោងសកម្មភាពតូចមួយនៅក្នុងសហគមន៍របស់ខ្លួន ដែលត្រូវបានផ្តល់មូលនិធិតាមលក្ខខណ្ឌជាក់លាក់ ។ គម្រោងសកម្មភាពផ្តល់ឱ្យអ្នកចូលរួមនូវឱកាសដើម្បីអនុវត្តចំណេះដឹងដែលបានសិក្សាពីកម្មវិធីនេះ ក្នុងការដោះស្រាយបញ្ហាប្រឈមនៃការអភិវឌ្ឍជាក់លាក់នៅក្នុងសហគមន៍របស់ពួកគេ ។

គម្រោងសកម្មភាពមានពីរដំណាក់កាល៖ ដំណាក់កាលទី១ (ការពិគ្រោះយោបល់ជាមួយសហគមន៍ និងកំណត់វិសាលភាព) និងដំណាក់កាលទី ២ (ការអនុវត្តនៅមូលដ្ឋាន) ។ ដំណាក់កាលទាំងពីរនេះធ្វើឡើងបន្ទាប់រៀនពីវគ្គសិក្សា SDC ផ្នែកទី២ គឺនៅពេលដែលអ្នកចូលរួមត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេ។ សិក្ខាកាមនឹងទទួលបានការបង្វឹក និងការគាំទ្រជាបន្តបន្ទាប់ពី UnionAID និង KFP/PAKA ពេញមួយដំណើរការនេះ។













## បណ្តាញអតីតសិក្ខាកាម

សន្និសីទអតីតសិក្ខាកាមត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំនៅកម្ពុជា ឬឡាវ។ សន្និសិទនេះបាននាំអតីតសិក្ខាកាមចូលរួមជាមួយគ្នាដើម្បីចែករំលែកការរៀនសូត្រពីកម្មវិធី និងកសាងទំនាក់ទំនងរយៈពេលវែង។ អតីតសិក្ខាកាមក៏ក្លាយជាផ្នែកមួយនៃបណ្តាញអ្នកដឹកនាំវ័យក្មេងរបស់ UnionAID ហើយអាចចូលរួមជាមួយមិត្តភ័ក្តិរបស់ពួកគេក្នុងកម្មវិធីនេះមកពីប្រទេសមីយ៉ាន់ម៉ា ឥណ្ឌូនេស៊ី និងមីនដាណាវ (ហ្វីលីពីន)។















## តើអ្នកនឹងទទួលបានអ្វីខ្លះពីកម្មវិធី CLYLP?

ការចូលរួមនៅក្នុងកម្មវិធី CLYLP នឹងកសាងចំណេះដឹង ទំនុកចិត្ត និងជំនាញរបស់អ្នកក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ភាពជាអ្នកដឹកនាំ ការស្រាវជ្រាវ និងទំនាក់ទំនង។ ការរៀនសូត្រ និងបទពិសោធន៍ដែលទទួលបានក្នុងកម្មវិធីនេះ នឹងជួយអ្នកឱ្យមានឥទ្ធិពលកាន់តែខ្លាំងលើការអភិវឌ្ឍប្រកបដោយចីរភាពនៅប្រទេសកម្ពុជា និងប្រទេសឡាវ និងអាចលើសពីនេះ ។ អតីតសិក្ខាកាមពីកម្មវិធីអ្នកដឹកនាំវ័យក្មេងរបស់យើងកន្លងមក បានបង្ហាញពីភាពជាអ្នកដឹកនាំប្រកបដោយគុណភាពតាមរយៈទទួលបានតួនាទីការងារខ្ពស់ ដោយទទួលយកនូវកិច្ចការមានទំនួលខុសត្រូវខ្ពស់នៅក្នុងសហគមន៍ និងកាន់តែសកម្មលើបញ្ហាថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។ អតីតសិក្ខាកាមជាច្រើនក៏ទទួលបានប្រភពថវិកាបន្ថែមទៀតដើម្បីកសាង ឬពង្រីកគម្រោងសកម្មភាពរបស់ពួកគេ។

សិក្ខាកាមបង្កើតទំនាក់ទំនងរឹងមាំជាមួយមិត្តភ័ក្តិរបស់ពួកគេ ក៏ដូចជាក្រុមគ្រួសារម្ចាស់ផ្ទះដែលពួកគេស្នាក់នៅ គ្រូបង្ហាត់បង្រៀន និងអង្គការនានានៅប្រទេសនូវែលសេឡង់។ អតីតសិក្ខាកាមបន្តទំនាក់ទំនង និងចូលរួមចំណែកដល់បណ្តាញទាំងនេះបានយ៉ាងល្អក្រោយពីការបញ្ចប់ការចូលរួមដោយផ្ទាល់ក្នុងកម្មវិធី ។



## ការស្នាក់នៅក្រុងAotearoaនៃប្រទេសនូវែលសេឡង់

ប្រទេសនូវែលសេឡង់ស្ថិតនៅភាគខាងត្បូងមហាសមុទ្រប៉ាស៊ីហ្វិក និងមានប្រជាជនចំនួន ៥ លាននាក់ ជាប្រទេសដែលមានពហុវប្បធម៌។ Maori គឺជាជនជាតិដើមភាគតិចនៅប្រទេសនូវែលសេឡង់។ ប្រទេសនូវែលសេឡង់មានការអភិវឌ្ឍសេដ្ឋកិច្ច និងជាប់ចំណាត់ថ្នាក់ទៀងទាត់ជាប្រទេសប្រជាធិបតេយ្យ និងមានអំពើពុករលួយតិចបំផុតមួយក្នុងពិភពលោក។

**Auckland - Tāmaki Makaurau** គឺជាទីក្រុងធំជាងគេរបស់ប្រទេសនូវែលសេឡង់ ដែលមានប្រជាជន ១,៥ លាននាក់ និងមានវប្បធម៌អាស៊ីប៉ាស៊ីហ្វិករឹងមាំ ។ បរិវេណសាកលវិទ្យាល័យ AUT ដែលភាគច្រើនវគ្គសិក្សា SDC ផ្នែកទី២ រៀបចំនៅទីនោះ ស្ថិតនៅកណ្តាលទីក្រុង ហើយអាចធ្វើដំណើរទៅមកតាមយានយន្តសាធារណៈ។

សិក្ខាកាមក៏នឹងទៅទស្សនារដ្ឋធានីWellington – Te Whanganui a Tara ផងដែរ ។ សិក្ខាកាមនឹងស្នាក់នៅជាមួយគ្រួសារនៅទីក្រុងAuckland ដែលម្ចាស់ផ្ទះជាមនុស្សរួសរាយរាក់ទាក់ និងជួយគាំទ្រ ។ អាហារបរិភោភាគច្រើនរបស់សិក្ខាកាមគឺផ្តល់ដោយម្ចាស់ផ្ទះដែលពួកគេស្នាក់នៅជាមួយ។

CLYLP ឧបត្ថម្ភមូលនិធិយ៉ាងពេញលេញដល់សិក្ខាកាម ។ សិក្ខាកាមទទួលបានប្រាក់ឧបត្ថម្ភដើម្បីគាំទ្រដល់ការចូលរួមរបស់ពួកគេក្នុងការសិក្សាតាមអនឡាញក្នុងប្រទេសកម្ពុជា និងប្រទេសឡាវ រួមទាំងការចំណាយសម្រាប់ចូលរួមក្នុងសិក្ខាសាលានៅក្នុងប្រទេសផងដែរ។

ថ្លៃសិក្សា ការធ្វើដំណើរទៅ និងមកពីប្រទេសនូវែលសេឡង់ និងទិដ្ឋាការត្រូវបានរៀបចំ និងបង់ប្រាក់ដោយអង្គការ UnionAID ។ ប្រាក់ឧបត្ថម្ភប្រចាំសប្តាហ៍សម្រាប់អាហារថ្ងៃត្រង់ ការធ្វើដំណើរ និងការចំណាយផ្សេងៗទៀតនឹងត្រូវបានផ្តល់ជូនដល់អ្នកចូលរួមម្នាក់ៗក្នុងអំឡុងពេលការស្នាក់នៅប្រទេសនូវែលសេឡង់។



















## តើនរណាខ្លះអាចដាក់ពាក្យស្នើសុំចូលរួមកម្មវិធីបាន ?

CLYLP ប្តេជ្ញាកសាងបណ្តាញអ្នកដឹកនាំវ័យក្មេងដែលឆ្លុះបញ្ចាំងពីភាពចម្រុះសហគមន៍នៃប្រទេសកម្ពុជា និងឡាវ។ យើងទទួលស្គាល់ និងផ្តល់តម្លៃដល់ទស្សនៈពិសេសប្លែកៗ បទពិសោធន៍ជីវិត ចំណេះដឹង កិច្ចប្រឹងប្រែងដោយខ្លួនឯង ជំនាញ និងទេពកោសល្យ ដែលអ្នកដឹកនាំវ័យក្មេងម្នាក់ៗនាំយកមកនៅក្នុងកម្មវិធី ។ ក្នុងការជ្រើសរើសអ្នកចូលរួម( សិក្ខាកាម ) យើងសូមស្វាគមន៍ចំពោះការរួមចំណែកជាពិសេសដែលបុគ្គលម្នាក់ៗអាចផ្តល់ជាគំនិត វប្បធម៌ ពូជពង្ស ពូជសាសន៍ ភាសាកំណើត អត្តសញ្ញាណយេនឌ័រ ភេទ ការអប់រំ សាសនា ស្ថានភាពអាពាហ៍ពិពាហ៍/គ្រួសារ (រួមទាំងភាពជាដៃគូជាក់ស្តែង) ស្ថានភាពមាតាបិតា ពិការភាព និងជំនឿ ។

**លក្ខណៈសម្បត្តិសម្រាប់ការជ្រើសរើស បេក្ខជនត្រូវ៖**

- ✓ មានអាយុ ២០-៣៥ ឆ្នាំ;
- ✓ រស់នៅ និងធ្វើការក្នុងប្រទេសកម្ពុជា ឬឡាវ (គ្រប់ខេត្តទាំងអស់មានសិទ្ធិទទួលបាន);
- ✓ ធ្វើការជាមួយសង្គមស៊ីវិល ឬអង្គការសហគមន៍ សហជីព ឬសហគ្រាសសង្គម;
- ✓ មានបំណងបន្តធ្វើការឱ្យអង្គភាពរបស់ខ្លួនរយៈពេលយ៉ាងតិចពីរឆ្នាំបន្ទាប់ពីបញ្ចប់កម្មវិធី;
- ✓ មានភាសាអង់គ្លេសកម្រិតមធ្យម ជំនាញស្មើនឹង **CEFR B1 / ≥4.5 IELTS /> TOEFL 32-34** (មិនទាមទារវិញ្ញាបនបត្រប្រឡងភាសាអង់គ្លេសឡើយ) * ;
- ✓ អាចចូលរួមក្នុងកម្មវិធីពេញម៉ោងរយៈពេល ២ សប្តាហ៍ក្នុងខែវិច្ឆិកា/ធ្នូ ឆ្នាំ ២០២៤ នៅក្នុងប្រទេសខ្លួន;
- ✓ មានការគាំទ្រក្នុងការចូលរួមក្នុងកម្មវិធីពីអង្គការដែលពួកគេតំណាង ឬធ្វើការឱ្យ រួមទាំងភាពបត់បែនក្នុងការចូលរួមវគ្គសិក្សាតាមអនឡាញក្នុងអំឡុងពេលម៉ោងធ្វើការ និងឈប់សម្រាកពីការងាររយៈពេល ១២ សប្តាហ៍ ដើម្បីចូលរួមក្នុងកម្មវិធីនៅប្រទេសណូវែលសេឡង់;
- ✓ មិនត្រូវចុះឈ្មោះចូលរៀនពេញម៉ោងនៅក្នុងវគ្គសិក្សាផ្សេងៗទៀតទេ(អាហារូបករណ៍) ក្នុងអំឡុងពេលចូលរួមវគ្គសិក្សា( SDC )ក្នុងកម្មវិធី;
- ✓ ពិភាក្សាជាមួយ UnionAID មុនពេលចុះឈ្មោះចូលរៀនវគ្គសិក្សាក្រៅម៉ោងផ្សេងទៀតក្នុងអំឡុងពេលសិក្សាវគ្គ SDC;
- ✓ មាន ឬអាចទទួលបានលិខិតឆ្លងដែនដែលមានសុពលភាពរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ ២០២៦



## របៀបដាក់ពាក្យស្នើសុំ

ដើម្បីដាក់ពាក្យស្នើសុំចូលរួមក្នុងកម្មវិធី អ្នកអាចចូលទៅកាន់គេហទំព័ររបស់ UnionAID ហើយបំពេញទម្រង់ពាក្យសុំតាមអនឡាញ រហូតដល់ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២៤ ។ នៅពេលទទួលពាក្យស្នើសុំទាំងអស់ បេក្ខជននឹងត្រូវបានចំរាញ់ជ្រើសរើសដោយ UnionAID សម្រាប់ធ្វើការបទសម្ភាសន៍នៅដើមខែសីហា ឆ្នាំ ២០២៤ ។ ការជ្រើសរើសចុងក្រោយសម្រាប់អ្នកចូលរួមចំនួន ១០ នាក់ នឹងត្រូវបានធ្វើឡើងបន្ទាប់ពីធ្វើបទសម្ភាសន៍ ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ ៖

www.unionaid.org.nz/young-leaders- programmes/clylp ឬ

KFPនៅកម្ពុជា តាមរយៈ Email: info@kfpcam.com ឬ

PAKA នៅប្រទេសឡាវតាមរយៈ Email: Paka2020.official@gmail.com

ចុចទីនេះ here សម្រាប់ទម្រង់ពាក្យសុំ

## លក្ខណៈវិនិច្ឆ័យជ្រើសរើស

ក្នុងការជ្រើសរើស បេក្ខជននឹងត្រូវបានវាយតម្លៃដោយប្រើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- បង្ហាញពីភាពជាអ្នកដឹកនាំ និងសក្តានុពលភាពជាអ្នកដឹកនាំនាពេលអនាគត។
- ការប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍ និងការងារសហគមន៍។
- ការប្តេជ្ញាចិត្តក្នុងការធ្វើការជាមួយក្រុមជនជាតិភាគតិច និងសាសនាដទៃទៀត។
- មានចិត្តទូលាយ និងភាពចាស់ទុំ;
- ការគាំទ្រពីអង្គការដែលពួកគេបំរើការងារ រួមទាំងការប្តេជ្ញាចិត្តទៅវិញទៅមក ដើម្បីបន្តការងារសម្រាប់រយៈពេលពីរឆ្នាំក្រោយចប់កម្មវិធី។
- ការកំណត់បញ្ហាប្រឈមនៃការអភិវឌ្ឍច្បាស់លាស់ និងមានភាពពាក់ព័ន្ធ ឬវិស័យដែលអ្នកចាប់អារម្មណ៍ចង់អនុវត្តតាមរយៈកម្មវិធីដែលអាចផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍគម្រោងសកម្មភាពនៅពេលចូលរួមក្នុងកម្មវិធីនេះ។
- ឆ្លុះបញ្ចាំងពីភាពចម្រុះជាតិសាសន៍ និងយេនឌ័រ តាមដែលអាចធ្វើទៅបាន ហើយទិដ្ឋកា(VISA) សិស្ស-និស្សិត នឹងត្រូវផ្តល់ជូន ដែលជាតម្រូវការអន្តោប្រវេសន៍។

For more information, go to www.unionaid.org.nz/young-leaders-programmes/clylp or email KFP in Cambodia info@kfpcam.com, or PAKA in Laos Paka2020.official@gmail.com

Click here for the application form



KFP TRADING CO.,LTD

ផ្ទះលេខ2929 ផ្លូវ1970
ភូមិរោងចក្រ សង្កាត់គោកឃ្លាំង
ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា ។
ទូរស័ព្ទ (+855 12 38 08 01) និង
(+855 92 999 311)
អ៊ីម៉ែល : info@kfpcam.com
គេហទំព័រ : www.kfpcam.com

PAKA
PARTICIPATORY DEVELOPMENT KNOWLEDGE AGENCY

ភូមិបាន ផុនផាណោ ស្រុកសយសេដ្ឋា
រដ្ឋធានីវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យឡាវ
ទូរស័ព្ទ +856 20 59 421 852
អ៊ីម៉ែល : paka2020.office.info@gmail.com
PAKA-Participatory Development Knowledge Agency

NEW ZEALAND
FOREIGN AFFAIRS & TRADE
Manatū Aorere

កម្មវិធីនេះឧបត្ថម្ភគាំទ្រដោយ **Aoteoroa New Zealand's International DevelopmentCoperation Programme Nga Hoe Tupu-mai-Tawhiti**